# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៣៥ សហវ

ភ្នំពេញ,ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ២០០៣

## ប្រកាសអន្តរក្រសួង

## ស្តីពីការបង្កើតរង្វាន់ឧបត្ថម្ភបុរេប្រទាន

## នៅក្រសួងបរិស្ថាន

* * * * *

## ឧបនាយករដ្ឋមន្ត្រី

## និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០ ន.ស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម / ១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២

-បានឃើញព្រះរាជក្រម លេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

- បានឃើញប្រកាសលេខ ០០៤ ស.ហវ.មប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញសារាចរណែនាំលេខ ០០៣ សហវម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរង្វាន់ឧបត្ថម្ភបុរេប្រទាន

-ឃើញប្រកាសលេខ ១២៩ ប្រក.សហវ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៧ស្តីពីការកំណត់ទឹកប្រាក់រង្វាន់ឧបត្ថម្ភបុរេប្រទានជំពូក ១១

សំរាប់ទូទាត់ចំណាយចាំបាច់លើដំណើរការរដ្ឋបាល សំភារៈ និង ជួសជុលតូច

-បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុបច្ចុប្បន្ន ។

**<u>សំរេច</u>**

<u>ប្រការ ១</u>: ត្រូវបានបង្កើតរដ្ឋទេយ្យបុរេប្រទានជំពូក ១១ នៅក្រសួងបរិស្ថាន ដើម្បីធ្វើការទូទាត់ចំណាយទាំងឡាយ ដែលមានចែងក្នុងមាត្រា ៦៤ នៃអនុក្រឹត្យលេខ ៨២ អន.ក្រប ចុះថ្ងៃទី ១៦ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ។

ចំនួនទឹកប្រាក់ជាអតិបរិមា នៃការចំណាយដែលអនុញ្ញាតឱ្យរដ្ឋទេយ្យករបុរេប្រទានធ្វើការទូទាត់ ត្រូវបានកំណត់ក្រិតក្រោម ៥០០.០០០រ០០ ( *<u>ប្រាំរយពាន់រៀលគត់</u>* ) តាមចំណាត់ថ្នាក់ចំណាយនិមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយ និង ប្រកាសអន្តរក្រសួង ។

<u>ប្រការ ២</u>: ចំនួនទឹកប្រាក់នៃរដ្ឋទេយ្យបុរេប្រទានជំពូក ១១ សំរាប់មួយជុំនៃឆ្នាំ ត្រូវបានកំណត់ត្រឹមចំនួន *<u>មួយរយដប់មួយលានពីររយម្ភៃប្រាំពាន់រៀលគត់</u>* ( ១១១.២២៥.០០០រ០០ )

<u>ប្រការ ៣</u>: សេចក្តីសំរេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

<u>ប្រការ ៤</u>: អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋាន ថវិកានីយកម្ម និង ហិរញ្ញកិច្ច ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទ ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងបរិស្ថានត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**រដ្ឋមន្ត្រីស្តីទី**

**អ៊ុក រ៉ាប៊ុន**

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ម៉ុក_ម៉ារ៉េត**

-កន្លែងទទួល:
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី "*ដើម្បីជូនជ្រាប*"
- ដូចប្រការ ៤ "*ដើម្បីមុខការ*"
-ឯកសារ-កាលប្បវត្តិ